国連カンボジア暫定機構（ＵＮＴＡＣ）の下での選挙から二十五年を経て平和と安定を達成したカンボジアが、一層発展していくことを強く期待しております。昨年、閣下から、日本が推進する「自由で開かれたインド太平洋戦略」に対する力強い支持を頂きました。日本は、カンボジアとの間で、地域及び国際社会の平和と繁栄のために共に手を携え貢献していく考えです。

この一年を通じて行われる「日カンボジア友好六十五周年」記念行事に、両国から多くの人々が参加し、意義深い交流が行われることを楽しみにしています。カンボジア王室の一層の御繁栄、閣下のますますの御健勝と御成功、カンボジア国民の皆様の更なる御多幸を心からお祈りいたします。

平成三十年二月

日本国内閣総理大臣

安倍晋三

カンボジア王国首相
フン・セン　閣下

本年、日本とカンボジア王国が、外交関係樹立から六十五周年の慶節を迎えたことに対し、日本国政府及び日本国民を代表して心より祝意を表し、閣下及びカンボジア国民の皆様と共に心から喜びを分かち合いたいと思います。

両国関係は、六十五年をかけて大きく発展しました。日本はカンボジアの和平と国造りに長きにわたり常に継続して寄り添ってきました。特にカンボジアは、我が国が初めて本格的なＰＫＯ部隊を派遣した国であり、日本の積極的平和主義の原点です。カンボジア和平の達成とその後の復興・開発の道のりを肩を並べて共に歩むことで、両国は強固な信頼の絆で結ばれました。閣下の卓越した指導力の下、国際社会の後押しを受けつつ、カンボジアが目覚ましい経済発展を遂げ、今日ではＰＫＯ部隊派遣国として世界の平和に大きく貢献していることに心から敬意を表します。

二〇一三年に私と閣下の相互訪問を通じて両国関係を「戦略的パートナシップ」に引き上げて以降、日本企業による投資増大に加え、つばさ橋竣工や直航便就航、そして本年の在シェムリアップ領事事務所の開所など、協力の成果が次々と結実しています。昨年、閣下が訪日された際に表明したとおり、日本としては、物流改善や人材育成、都市機能強化にかかる支援拡充を進めることで、カンボジアの更なる発展を後押ししていく考えです。

**គោរពជូន សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

សម្តេចតេជោ ជាទីគោរព និងស្រលាញ់បំផុត

ខ្ញុំសូមចូលរួមជាមួយសម្តេចតេជោ និងប្រជាជនកម្ពុជាទាំងអស់ ដើម្បីអបអរសាទរខួបអនុស្សាវរីយ៍ ៦៥ឆ្នាំនៃកាបង្កើតទំនាក់ទំនងការទូតរវាងប្រទេសជប៉ុន និងព្រះរាជាណាចក្រកម្ពុជា។

ក្នុងអំឡុងពេល៦៥ឆ្នាំនេះ ទំនាក់ទំនងរវាងប្រទេសយើងទាំងពីរមានការអភិវឌ្ឍយ៉ាងខ្លាំង។ ប្រទេសជប៉ុនតែងតែនៅជាមួយប្រទេសកម្ពុជាក្នុងដំណើរការកសាងសន្តិភាព ការស្តារ និងកសាងប្រទេសឡើងវិញ។ ជាពិសេស កម្ពុជាជាប្រទេសដំបូងដែលជប៉ុនបានបញ្ជូនកងកម្លាំងស្វ័យការពារជប៉ុនមកចូលរួមថែរក្សាសន្តិភាព ហើយនោះ គឺជាចំណុចចាប់ផ្តើមនៃគោលនយោបាយរបស់ជប៉ុនក្នុងការចូលរួមថែរក្សាសន្តិភាពពិភពលោកយ៉ាងសកម្ម។

មិត្តភាព និងទំនុកចិត្តត្រូវបានកសាងឡើងរវាងប្រទេសយើងទាំងពីរ តាមរយៈការចាប់ដៃគ្នា ពោះជំហានរួមគ្នាឈានដល់ការសម្រេចបាននូវសន្តិភាព ការកសាងប្រទេសឡើងវិញ និង ការអភិវឌ្ឍរបស់កម្ពុជា។

ខ្ញុំសូមសម្តែងនូវអំណរសាទរដោយស្មោះអស់ពីដួងចិត្តចំពោះប្រទេសកម្ពុជាដែលសម្រេចបាននូវការអភិវឌ្ឍសេដ្ឋកិច្ចដ៏គួរឲ្យកត់សម្គាល់ជាមួយការគាំទ្រពីសហគមន៍អន្តរជាតិ និង បាននិងកំពុងចូលរួមចំណែកយ៉ាងសស្រាក់សស្រាំក្នុងសកម្មភាពថែរក្សាសន្តិភាពពិភពលោក ជាប្រទេសមួយដែលបានបញ្ជូនកងកម្លាំងថែរក្សាសន្តិភាពក្រោមការដឹកនាំរបស់សម្តេចតេជោ។

ក្រោយពេលដែលសម្តេចតេជោ និងខ្ញុំបានឯកភាពបង្កើនទំនាក់ទំនងរវាងប្រទេសយើងទាំងពីរទៅជា«ដៃគូយុទ្ធសាស្ត្រ»មក យើងទទួលបាននូវផ្លែផ្កាជាច្រើនជាបន្តបន្ទាប់ ដូចជា ការកើនឡើងនៃការវិនិយោគរបស់ក្រុមហ៊ុនជប៉ុន ការសម្ពោធស្ពានត្សឹបាសានៅអ្នកលឿង ការប្រារព្ធឡើងនៃជើងហោះហើរត្រង់រវាងជប៉ុន និងកម្ពុជា និងការបើកការិយាល័យកុងស៊ុលរបស់ជប៉ុនប្រចាំសៀមរាបជាដើម។

តាមអ្វីដែលខ្ញុំបានប្រកាសកាលពីដំណើរទស្សនកិច្ចរបស់សម្តេចតេជោនៅប្រទេសជប៉ុននៅឆ្នាំមុន ប្រទេសជប៉ុនមានជំហរបន្តផ្តល់ការគាំទ្រការអភិវឌ្ឍបន្ថែមទៀតដល់កម្ពុជា តាមរយៈការបន្ថែមជំនួយក្នុងការកែលម្អឡូជីស្ទិក បណ្តុះបណ្តាលធនធានមនុស្ស និងការពង្រឹងមុខងារទីក្រុង។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំចំពោះការរីកចំរើនរបស់កម្ពុជាដែលបានឆ្លងកាត់រយៈពេល២៥ឆ្នាំ ក្រោយការបោះឆ្នោតដែលរៀបចំឡើងដោយអ៊ុនតាក់។ តាំងពីឆ្នាំមុនមក សម្តេចតេជោ បានផ្តល់ការគាំទ្រដ៏មានតម្លៃចំពោះ «យុទ្ធសាស្ត្រ ឥណ្ឌាប៉ាស៊ីហ្វិកសេរី និងបើកចំហរ» ដែលប្រទេសជប៉ុនបាននិងកំពុងជំរុញ។ ប្រទេសជប៉ុននឹងបន្តរួមសហការជាមួយប្រទេសកម្ពុជា ដើម្បីរួមចំណែកដល់សន្តិភាព និងវិបុលភាពក្នុងតំបន់ និងនៅលើពិភពលោក។

ខ្ញុំសង្ឃឹមថា ប្រជាជននៃប្រទេសយើងទាំងពីរ នឹងចូលរួមយ៉ាងកុះករក្នុងកម្មវិធីអនុស្សាវរីយ៍ «ខួប៦៥ឆ្នាំនៃមិត្តភាពរវាងជប៉ុន និង កម្ពុជា» ព្រមទាំងការផ្លាស់ប្តូរទំនាក់ទំនងនានាដ៏មានអត្ថន័យជាច្រើនទៀត។ ខ្ញុំសូមថ្វាយព្រះពររាជវង្សានុវង្សកម្ពុជា សូមមានសេចក្តីរីកចំរើន សូមជូនពរសម្តេចតេជោ សូមមានសុខភាពល្អ និងជោគជ័យគ្រប់ភារកិច្ច សូមជូនពរប្រជាជនកម្ពុជា សូមមានសុភមង្គលគ្រប់ៗគ្នា។

ខែ កុម្ភៈ ឆ្នាំ២០១៨

**ស៊ីនហ្សូ អាបេ**

នាយករដ្ឋមន្ត្រី នៃប្រទេសជប៉ុន